ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ១៦០៣/២២ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២២

# របាយការណ៍
# វឌ្ឍនភាពការងារ ៩ខែដើមឆ្នាំ និងទិសដៅការងារត្រីមាសទី៤ ឆ្នាំ២០២២
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

រយៈពេល ៩ខែដើមឆ្នាំ២០២២ កន្លងទៅនេះ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចអនុវត្ត ផែនការសកម្មភាពរួម ៧៧,៣% ដែលក្នុងនោះការអនុវត្តផ្លូវជនបទសម្រេចបាន ៨០% អត្រាទទួល បានសេវាទឹកស្អាតមូលដ្ឋានជនបទ ៧៨,៥៧% និងសេវាអនាម័យមូលដ្ឋាន ៨០,៦៦% គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ នេះ និងសេវាផ្សេងៗសម្រេចបាន ៧០% ។

ខេត្តព្រៃវែង កំពុងត្រូវបានវាយតម្លៃជាខេត្តទទួលបានការបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ទី២ បន្ទាប់ពីខេត្តស្វាយរៀង និងកំពុងបន្តពិនិត្យបណ្តាខេត្តមួយចំនួនដែលនឹងអាចក្លាយជាខេត្ត ODF ជាបន្តបន្ទាប់ទៅតាមគោលដៅដែលបានកំណត់ ។ កិច្ចសហប្រតិបត្តិការជាមួយគម្រោងដៃគូ អង្គការក្រៅរដ្ឋាភិបាល និងបណ្តាប្រទេសអាស៊ាន បានប្រព្រឹត្តទៅល្អប្រសើរ និងមានវឌ្ឍនភាពគួរឲ្យកត់សំគាល់ ។

ទន្ទឹមនឹងមានវឌ្ឍនភាពល្អប្រសើរក៏មានបញ្ហាប្រឈម ក្នុងរយៈពេល ៩ខែដើមឆ្នាំនេះផងដែរ គឺមានជំនន់ទឹកភ្លៀងដែលបានហូរច្រោះដាច់តួផ្លូវ និងជើងទេរផ្លូវនៅខេត្តចំនួន ០៦ ក្នុងស្រុកចំនួន ៣៧ ដូចមានក្នុងរបាយការណ៍នេះស្រាប់។

ជាលទ្ធផលក្រសួងសម្រេចបានដូចខាងក្រោម៖

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការថវិកាតាមកម្មវិធីក្នុងរយៈពេល ៩ខែដើមឆ្នាំ នៅទូទាំងប្រទេសសម្រេចបាន ប្រមាណស្មើនឹង ៧៧,៣០ % នៃផែនការថវិកាឆ្នាំ២០២២ ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតដល់ដំណាច់ខែកញ្ញា ឆ្នាំ ២០២២ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៤៩១ នាក់ (ស្រីចំនួន ៤០៩ នាក់) ។ក្រសួងបានទទួលលិខិតចូលចំនួន ១ ១៥០ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន



អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 884 639 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

១៤៤១ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៥៨ ច្បាប់ និងចុះលេខលិខិតបេសកកម្ម ចំនួន ១ ២៥៤ ច្បាប់ ។

**២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

ក្នុង ៩ខែដើមឆ្នាំ ២០២២ នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២២ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ១៧,៥៩ %នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៨០,៥៨% នៃច្បាប់ថវិកា ។

**២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍ប្រចាំត្រីមាស ទី១ និងទី២ ឆ្នាំ២០២២ របស់អគ្គលេខាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមវគ្គបណ្តុះបណ្តាលអនឡាញស្តីពីការពង្រឹងតម្លាភាពសារពើពន្ធសម្រាប់កិច្ចអភិវឌ្ឍន៍ " Advance Fiscal Transparency for Development"
- ផ្តល់ធាតុចូលសម្រាប់វាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ផ្នែកចំណូលមិនមែនសារពើពន្ធពាក់កណ្តាលអាណត្តិ
- ចូលរួមសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធី ដែលរៀបចំឡើងដោយអគ្គលេខាធិការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ
- រៀបចំរបាយការណ៍ត្រីមាសទី៤ និងរបាយការណ៍ប្រចាំឆ្នាំនៃការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធអនឡាញ
- ចូលរួមពិភាក្សាបញ្ចប់ និងការអនុម័តផែនការសកម្មភាពជំណាក់កាលទី៣+២(MAP3+2) សម្រាប់ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ
- រៀបចំសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំការរៀបចំថវិកាសមិទ្ធកម្ម និងការសរសេរសូចនាករសមិទ្ធកម្មសម្រាប់រាជធានីខេត្តចំនួន ១៣ ដោយមានសិក្ខាកាម ចូលរួមចំនួន ៨៣ នាក់ នៅសណ្ឋាគារ Empress Angkor and Spar រយៈពេល ០២ ថ្ងៃ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការសកម្មភាពរួមដំណាក់កាលទី៤នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ PFMRP ២០២៣-២០២៧
- រៀបចំសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងថវិកាព័ត៌មានសមិទ្ធកម្មឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ នៅខែមិថុនា ឆ្នាំ២០២២ ។

**២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ**

(គ្មានសកម្មភាព)

២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំកិច្ចប្រជុំបូកសរុបការងារត្រីមាសទី៣ ឆ្នាំ២០២២ និងទិសដៅបន្ត របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- ចូលរួមកិច្ចប្រជុំមេគង្គឡានឆាង ស្ដីពីតួនាទីកិច្ចសហប្រតិបត្តិការក្នុងតំបន់មេគង្គដែលរៀបចំឡើងដោយប្រទេសមីយ៉ាន់ម៉ា តាមប្រព័ន្ធវីដេអូអនឡាញ
- ចូលរួមប្រជុំពិភាក្សាការរៀបចំ ASEAN MASTER PLAN on Rural Development 2022-2026 ចំនួន ០២ ដង តាមអនឡាញ និងដោយផ្ទាល់នៅទីក្រុងហាណូយ
- ចូលរួមប្រជុំពិភាក្សាអំពីរបាយការណ៍វាយតម្លៃការខូចខាតហេដ្ឋារចនាសម្ព័ន្ធជនបទដោយជំនន់ទឹកភ្លៀងសម្រាប់រាជធានី-ខេត្តទាំង២៥ នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំពិភាក្សាជាមួយជំនាញការធនាគារអភិវឌ្ឍន៍អាស៊ីស្ដីពី Project Document Facilities (PDF) ការរៀបចំ ការអនុវត្តគម្រោងវិនិយោគសាធារណៈ និងថវិកាជាតិ
- រៀបចំវេទិកា ASEAN Forum on Poverty Eradication and Rural Development នៅខេត្តសៀមរាប ដោយមានការចូលរួមពីបណ្ដាសមាជិកអាស៊ាន អង្គការ NGOs ក្នុង ស្រុក ចំនួន ០៣ និង សមាគមកសិករខ្មែរ
- ចូលរួមពិភាក្សាជាមួយអគ្គរដ្ឋទូត ឥណ្ឌា ប្រចាំប្រទេសកម្ពុជា ដែលដឹកនាំដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ទាក់ទងនិងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអាទិភាព និងលទ្ធផលដែលក្រសួងសម្រេចបានកន្លង ពិសេសកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឥណ្ឌា ក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលរយៈពេល ០២ ថ្ងៃ ស្ដីពីការយល់ដឹងពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងថវិកាព័ត៌មានសមិទ្ធកម្មឆ្នាំ២០២៣ សម្រាប់វិស័យ ផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទសម្រាប់ ១៣ខេត្ត នៅខេត្តសៀមរាប ក្រោមអធិបតីភាព **ឯកឧត្តម ថោង ពោជ** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ ២០១៩-២០២២
- សម្របសម្រួល និងប្រមូលឯកសារផ្លូវការស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងថវិកាព័ត៌មានសមិទ្ធកម្មឆ្នាំ២០២៣ របស់អង្គភាពថ្នាក់កណ្ដាល និងថ្នាក់រាជធានី-ខេត្ត
- ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២៣ ២០២៥ តាមប្រព័ន្ធអនឡាញ-Zoom ដែលរៀបចំដោយទីស្ដីការគណៈរដ្ឋមន្ត្រី
- ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីលទ្ធផលបឋមនៃការសិក្សាវាយតម្លៃតម្រូវការបណ្ដុះបណ្ដាលការងារផែនការ គោលនយោបាយ និងការតាមដានត្រួតពិនិត្យ វាយតម្លៃ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការសកម្មភាពរួមដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧ តាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពី ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផ.ជ.អ.យ.រៀបចំដោយ ក្រសួងផែនការ
- ចូលរួមវេទិកាសាធារណៈថ្នាក់ជាតិស្តីពី ការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការនៃការកសាងផែនការថវិកា និងការតាមដានលើចំណូល ចំណាយថវិកាសាធារណៈ ក្នុងបរិបទក្រោយកូវីដ-១៩ រៀបចំដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល
- សម្របសម្រួលឯកសារកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) ៣ឆ្នាំរំកិល ២០២៣-២០២៥ របស់អង្គភាពថ្នាក់កណ្តាលក្រោមឱវាទក្រសួង
- ចុះត្រួតពិនិត្យផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ខេត្តព្រះវិហារ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង និងខេត្តរតនគិរី
- បញ្ចូលរបាយការណ៍សមិទ្ធកម្មត្រីមាសទី១ អង្គភាពក្រោមឱវាទក្រសួង
- ចូលរួមរៀបចំតារាងបូកសរុប សមិទ្ធផល ០៥ឆ្នាំ ២០១៨-២០១៩ សម្រាប់នាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទ
- ចុះបេសកកម្មនៅខេត្តបាត់ដំបងដើម្បីតាមដាន និងវាយតម្លៃលើការងារអនុវត្តថវិកាកម្មវិធី
- បានរៀបចំបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០៩ កិច្ចព្រមព្រៀង
- បានរៀបចំលិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០៨
- បានរៀបចំលិខិតគាំទ្រ ទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ចំនួន ០៤លិខិត
- បានរៀបចំលិខិតសុំអន្តរាគមន៍ ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០៧
- បានរៀបចំលិខិតគាំទ្រ ដើម្បីធ្វើការប្តូរស្លាកលេខពីទម្រង់ចាស់ទៅទម្រង់ថ្មី អង្គការមិនមែនរដ្ឋាភិបាល ជូនអង្គការចំនួន ០១
- បានរៀបចំលិខិតសុំផ្លាស់ប្តូរទិដ្ឋាការពីប្រភេទ E និង EB មកប្រភេទ C ជូនបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ចំនួន ០៣ លិខិត
- បានរៀបចំ របាយការណ៍វឌ្ឍនភាព សមិទ្ធផលការងារដែលបានសម្រេចកន្លងមក នៃកិច្ចសហប្រតិបត្តិការកម្ពុជា-នូវែលសេឡង់ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ

- បានរៀបចំករណីសំណើសុំផ្តល់មតិលើសេចក្តីព្រាងផែនការសកម្មភាពដើម្បីអនុវត្តជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហភាពអឺរ៉ុប ឆ្នាំ (២០២៣-២០២៥)
- បាន Upload និង Post ឯកសារចូលទៅក្នុងគេហទំព័រក្រសួង
- បានជួសជុលកុំព្យូទ័រ និងដំឡើងកម្មវិធី Ms. Office ជូនមន្ត្រីក្នុងក្រសួង ត្រួតពិនិត្យ និងដោះស្រាយបញ្ហា Network/Internet បញ្ហាកុំព្យូទ័រ និងម៉ាស៊ីនព្រីនធ័រជូនថ្នាក់ដឹកនាំ និងតាមនាយកដ្ឋាន
- បានធ្វើបច្ចុប្បន្នភាពលើម៉ាស៊ីន Server
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

**២.២.៦. ការងារអធិការកិច្ច និងសវនកម្ម**

- បានចុះធ្វើសវនកម្មលើថវិកាកម្មវិធីនៅមន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥ រាជធានី-ខេត្ត
- បានចុះធ្វើសវនកម្មគ្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ បានចំនួន ០៦ ខេត្ត គឺខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តសៀមរាប
- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០២១ នៅគ្រប់មន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី-ខេត្ត ។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- គម្រោងថែទាំខួប ឆ្នាំ ២០២២ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៤៨ ខ្សែ ប្រវែងសរុប ៣៥១,៨៨ គ.ម លូមូល ៤៨ កន្លែង និងលូប្រអប់ ០៦ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមអនុវត្តបាន ៨៥ %
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២២ សរុបចំនួន ៣៧ គម្រោង ស្មើនឹង ៣៦១ ខ្សែ ប្រវែងសរុប ៣ ៤៤៩,៥០ គ.ម លូមូល ០២ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៤៥ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមអនុវត្តបាន ៨០ %
- គម្រោងស្ថាបនា កែលម្អ និងជួសជុល ឆ្នាំ២០២២ សរុបចំនួន ៥៤ គម្រោង ក្នុងនោះមានគម្រោងពេញសិទ្ធិមានចំនួន ២៧ គម្រោង និងបម្រុងចំនួន ២៧ គម្រោង សរុបប្រវែង ២១៧,៣៥ គ.ម សម្រេចលទ្ធផលគិតជាមធ្យមបាន ៥៥,៨៣ %
- បានចុះត្រួតពិនិត្យ និងវាយតម្លៃ ចំនួន ១០២ គម្រោង ក្នុងនោះគម្រោងជំពូក ២១ ចំនួន ២៩ គម្រោង និងគម្រោងជំពូក ៦១ ចំនួន ៧៣ គម្រោង
- ទទួលសំណាកគំរូបានចំនួន ២៧៩ សំណាករណ្តៅ
- ធ្វើពិសោធន៍បានរួចរាល់១០០% បានចំនួន ៥៦៩ សំណាករណ្តៅ។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានចុះអប់រំ ផ្សព្វផ្សាយជូនប្រជាពលរដ្ឋតាមខ្នងផ្ទះឱ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត នៅខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តមណ្ឌលគិរី ខេត្តសៀមរាប ខេត្ត

កោះកុង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តកំពត ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ ខេត្តកែប ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ

- បានចុះប្រមូលទិន្នន័យការងារផ្គត់ផ្គង់ទឹកស្អាតជនបទ សម្រាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍ផ្នែកគោលនយោបាយក្នុងការជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព នៅខេត្តកំពង់ស្ពឺ និងខេត្តបាត់ដំបង
- បានសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ១៨៤ អណ្តូង នៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តក្រចេះ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន
- បានជីកស្តារស្រះសហគមន៍ ចំនួន ០៣ ស្រះ នៅខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់ និងខេត្តតាកែវ
- បានសាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ចំនួន ០៣ កន្លែង នៅខេត្តសៀមរាប និងខេត្តប៉ៃលិន
- បានជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ១៥០ អណ្តូង នៅខេត្តកំពង់ស្ពឺ ខេត្តរតនគិរី ខេត្តពោធិ៍សាត់ និងខេត្តព្រៃវែង
- បានសាងសង់អណ្តូងស្នប់ ចំនួន ២៣០ អណ្តូង នៅខេត្តកំពង់ស្ពឺ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តបាត់ដំបង
- បានសាងសង់ពាង ចំនួន ៤ ៤៣៧ ពាង នៅខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ
- បានសាងសង់ស្ថានីយផលិតទឹកផឹកសហគមន៍ ចំនួន ៣៦ ស្ថានីយ នៅខេត្តប៉ៃលិន ខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ។

**២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- រៀបចំកិច្ចប្រជុំក្រុមការងារ MIS ថ្នាក់ជាតិក្នុងគោលបំណងបែងចែកភារកិច្ច និងទំនួលខុសត្រូវការងារ MIS ថ្នាក់ខេត្ត
- ចូលរួមសម្របសម្រួលដល់អង្គការវឌ្ឍនភាពខេត្តស្ទឹងត្រែងធ្វើទស្សនកិច្ចសិក្សាពីចំណុចខ្លាំងខេត្តODF របស់ខេត្តស្វាយរៀង
- ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពីការអនុវត្ត (CLTS) នៅខេត្តកែប ខេត្តព្រះសីហនុ និងខេត្តឧត្តរមានជ័យ
- ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពីអនាម័យក្នុងបរិស្ថានប្រឈមនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ចុះផ្ទៀងផ្ទាត់ទិន្នន័យបង្គន់តាមខ្នងផ្ទះ និងជំរុញផ្ទះដែលមិនទាន់សាងសង់បង្គន់អនាម័យក្នុងស្រុកសំរោង និងបានចុះផ្ទៀងផ្ទាត់ស្រុក(ODF)ក្នុងស្រុកស្រីស្នំ ខេត្តតាកែវ
- បានចុះពិនិត្យមើលទីតាំងដាក់បង្គន់អនាម័យនៅតាមភូមិគោលដៅទាំង ១៣ ខេត្តរួមមានៈ

ខេត្តកែប ខេត្តព្រះសីហនុ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តព្រះវិហារ ខេត្តពោធិ៍សាត់ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកោះកុង

- ប្រជុំពិនិត្យផែនការឃុំ ODF និងការបែងចែកថវិកាឃុំសម្រាប់កម្មវិធីទឹកស្អាត និងអនាម័យ
- ចុះបំផុសសកម្មភាពអនាម័យចំនួន ០៥ ភូមិ ក្នុងស្រុកឆែប ខេត្តព្រះវិហារ
- ចុះផ្ទៀងផ្ទាត់ODFក្នុងខេត្តព្រៃវែងដើម្បីឈានទៅប្រកាសជាខេត្តODF
- ចុះពិនិត្យតាមដានការប្រើប្រាស់បង្គន់អនាម័យក្នុងអង្គភាពរដ្ឋនិងសេវាឯកជនតាមខេត្ត
- ចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីលទ្ធផលផ្ទៀងផ្ទាត់ODFខេត្តព្រៃវែង
- ចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការធ្វើឲ្យប្រសើរឡើងវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអាកាសធាតុក្នុងតំបន់
- ចូលរួមប្រជុំកម្មវិធីលើកកម្ពស់ទឹកស្អាត និងអនាម័យជនបទនៅខេត្តកែបដើម្បីពង្រឹងយន្តការដឹកនាំសម្របសម្រួលថ្នាក់ខេត្ត
- ប្រជុំជាមួយសហគមន៍ក្នុងស្រុកដំណាក់ចង្អើរជំរុញគ្រួសារមិនទាន់មានបង្គន់អនាម័យឲ្យសាងសង់បង្គន់
- ចុះពិនិត្យតាមដានវឌ្ឍនៈភាពផែនការ ODF ចំនួន ០៨ ឃុំ ក្នុងស្រុកសំរោងទងក្នុងនោះឃុំចំនួន ០៥ ជិតសម្រេចបានឃុំODF
- បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ(MIS)បែបឌីជីថលក្នុងវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងលើកកម្ពស់អនាម័យសម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ប្រជុំជាមួយអង្គការ Unicef/WHO ដើម្បីវាស់វែងសូចនាករទឹកស្អាត និងអនាម័យ MIS សម្រាប់ឆ្នាំ២០២២
- បានរៀបចំសិក្ខាសាលាអំពីកញ្ចប់បណ្តុះបណ្តាលពីហានិភ័យអាកាសធាតុលើវិស័យ (WASH) សម្រាប់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទថ្នាក់ជាតិ និងក្រោមជាតិ
- រៀបចំកិច្ចប្រជុំក្រុមការងារ DWG-RWSSH ស្តីពីបញ្ហាប្រឈម និងដំណោះស្រាយការអនុវត្តផែនការ ODF និងរាយការណ៍ពីស្ថានភាពអនាម័យ
- ចុះសិក្សាទីតាំងសាងសង់បង្គន់អនាម័យតាមព្រំដែនសម្រាប់ពលករចំណាកស្រុកទៅប្រទេសថៃ
- បានចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យប្រតិបត្តិអនាម័យល្អនៅតាមគ្រួសារទាំង១៥ខេត្តគោលដៅរួមមានៈ ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តប៉ៃលិន ខេត្តកែប និងខេត្តព្រៃវែង ។

### ២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- ពិភាក្សាការងារធ្វើបច្ចុប្បន្នភាព និងការពង្រឹងសមត្ថភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

- ចុះសិក្សាដើម្បីកំណត់ភូមិគោលដៅគម្រោងអភិវឌ្ឍន៍ភូមិ នៅខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ
- ចុះពិនិត្យគម្រោងអភិវឌ្ឍន៍ភូមិចម្រុះនៅខេត្តព្រៃវែង ខេត្តស្ទឹងត្រែង និងខេត្តសៀមរាប
- ចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តរតនគិរី ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តស្ទឹងត្រែង ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ និងខេត្តបន្ទាយមានជ័យ
- ចុះពិនិត្យ និងតាមដានសកម្មភាពគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារនៅខេត្តសៀមរាប និងខេត្តព្រះសីហនុ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីគោលការណ៍ណែនាំ និងឧបករណ៍ដើម្បីជំរុញការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅតំបន់ភាគខាងជើងប្រទេសកម្ពុជា
- ចុះពិនិត្យទីតាំងដែលដែលជួបគ្រោះមហន្តរាយ និងពិនិត្យមើលកន្លែងត្រៀមរៀបចំវគ្គបណ្តុះបណ្តាល សម្រាប់ឆ្នាំ ២០២២
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍នៅខេត្តបន្ទាយមានជ័យ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការកាត់បន្ថយផលប៉ះពាល់សកម្មភាពកសិកម្មលើតំបន់ដីសើម នៃតំបន់ដីសណ្តទន្លេមេគង្គក្រោម
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្រោមជ្ឈមណ្ឌល ចំនួន ១០ វគ្គ មានសិក្ខាកាមចំនួន ២០០ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានជូនដំណឹងស្តីពីការជ្រើសរើសសិក្ខាកាមសម្រាប់បើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់គ្រប់ចំនួន សរុបការជ្រើសរើសសិក្ខាកាមបានចំនួន ០៥ វគ្គ មានសិក្ខាកាមចំនួន ៦៦ នាក់ ខ្វះ ១០៥ នាក់ ។

### ២.២.១១. ការងារបណ្តុះបណ្តាល

- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់មន្រ្តីរាជការទាំងពីរភេទរបស់ក្រសួងអភិវឌ្ឍន៍ជនបទទាក់ទងនឹងអាហារូបករណ៍ និងព័ត៌មានផ្សេងៗបានចំនួន ២៤ លើក
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្រ្តអភិវឌ្ឍន៍សមត្ថភាពសហគមន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានរៀបចំឯកសារបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសបានចំនួន ២៤ លើក
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៨៤ នាក់ ក្នុងនោះស្រី ៨៨ នាក់
- មន្ត្រីចូលរួមវគ្គសិក្ខាសាលាក្នុងប្រទេស ចំនួន ១ ១៨២ នាក់ ក្នុងនោះស្រី ១៤២ នាក់

- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១១ ខេត្ត រួមមាន ៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល បានអនុវត្តសកម្មភាពបណ្តុះបណ្តាលបាន ៥៩ វគ្គ សិក្ខាកាមសរុប ១១៣៧ នាក់ ស្រី ៤៧៤ នាក់ ដោយវគ្គបណ្តុះបណ្តាលរយៈពេលវែងចំនួន ២៦ វគ្គ មានសិក្ខាកាមចំនួន ៤៧០ នាក់ ស្រី ១៨៣ នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីមានចំនួន ៣៣វគ្គ មានសិក្ខាកាមចំនួន ៦៦៧នាក់ ស្រី ២៩៦ នាក់ ។

## ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយ សហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៣ ៦៥៦ ៩៤៤ ៥៧៥ រៀល (បីប៊ីលានប្រាំមួយរយហាសិបប្រាំមួយលានប្រាំបួនរយសែសិបបួនពាន់ប្រាំរយចិតសិបប្រាំរៀល) ស្មើនឹង ៩៨៦ ៦៦៩,៤៧ ដុល្លារអាមេរិក (ប្រាំបួនរយប៉ែតសិបប្រាំមួយពាន់ប្រាំរយហុកសិបប្រាំបួនដុល្លារនិងសែសិបប្រាំពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៣ ១៦៩ នាក់ស្រី ចំនួន ២ ៥០៤ នាក់ នៅភូមិគោលដៅចំនួន ១៧៩ ភូមិ ៦៧ ឃុំ ៣០ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងឥណទានជនបទ ចំនួន ០៤ លើក នៅខេត្តកំពត ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ
- បានចុះពិនិត្យ គាំទ្រ និងតាមដានដំណើរការបណ្តុះបណ្តាលសហគមន៍សន្សំប្រាក់ចំនួន ០១ វគ្គ នៅភូមិអាឡែង ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុប ២៤នាក់ ស្ត្រី ១២នាក់
- បានរៀបចំសិក្ខាសាលាស្តីពីការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈម របស់សហគមន៍សន្សំប្រាក់ នៅខេត្តកំពង់ចាម ដែលមានសិក្ខាកាមមកពីមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត ទាំង២៥ និងសមាជិកសហគមន៍សន្សំប្រាក់មកពីខេត្តមួយចំនួន សរុបប្រមាណ ៥៥ នាក់ ស្ត្រី ១០ នាក់
- បានរៀបចំសិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលប្រចាំឆ្នាំលើការងារឥណទានជនបទ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាបមានអ្នកចូលរួមសរុបចំនួន ៥០នាក់ ស្រី ១៤នាក់
- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងសិប្បកម្មផលិតសាប៊ូ នៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ
- បានចុះបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូ ចំនួន ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ និងខេត្តសៀមរាប
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច នៅ

ភូមិត្បែង ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០១វគ្គ កាលពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០២២ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៣១ នាក់ ស្រី ១៤ នាក់

- បានរៀបចំតាំងពិព័រណ៌ផលិតផលជនបទ នៅខេត្តស្វាយរៀង ។

**២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- រៀបចំកម្មវិធីអបអរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៨ និងលើកទី១៨ នៅកម្ពុជា ក្រោមប្រធានបទៈ តួនាទីស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងការផ្ទេរចំណេះដឹងប្រពៃណី ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ ក្រសួងអភិវឌ្ឍន៍ជនបទ
- ដឹកនាំក្រុមការងារចុះជួបជាមួយថ្នាក់ដឹកនាំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី ក្នុងគោលបំណងជួបសំណេះសំណាលពិភាក្សាការងារ ដើម្បីពន្លឿនការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- ចូលរួមកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុង ស្តីពីការគ្រប់គ្រង ប្រើប្រាស់ដី និងធនធានធម្មជាតិសហគមន៍ជនជាតិដើមភាគតិច គ្រឹង នៅភូមិចាន់ ឃុំតាវែងលើ ស្រុកតាវែង និងសហគមន៍ជនជាតិដើមភាគតិច កាចក់ នៅភូមិកាក់ ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី
- ចូលរួមកិច្ចប្រជុំ ស្តីពីក្របខណ្ឌផែនការជនជាតិដើមភាគតិចសម្រាប់ការលើកកម្ពស់ភាពធន់នឹងអាកាសធាតុ និងការគ្រប់គ្រងទឹកចម្រុះនៅក្នុងតំបន់ងាយរងគ្រោះជនបទ នៃអាងទន្លេមេគង្គ ជាមួយលោកស្រី Susan Vauquelin ទីប្រឹក្សាអន្តរជាតិតំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FOA) អំពីបញ្ហាយេនឌ័ររបស់ស្ត្រីជនជាតិដើមភាគតិច នៅតាមសហគមន៍ជនបទ និងសមិទ្ធផលមួយចំនួនដែលនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចសម្រេចបានកន្លងមក
- ចូលរួមជាវាគ្មិនកិត្តិយសក្នុងសិក្ខាសាលាពិគ្រោះយោបល់ផ្តល់ធាតុចូលទៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ព្រៃឈើ ក្នុងគោលបំណងដើម្បីផ្តល់ធាតុចូលសំខាន់ៗជាផ្លូវការ និងដើម្បីធានាថាការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ព្រៃឈើ មានការចូលរួមផ្តល់យោបល់ពេញលេញពីសម្លេងបងប្អូនជនជាតិដើមភាគតិច និងអង្គការពាក់ព័ន្ធ ដោយបញ្ចៀសបាននូវភាពអសកម្មនានាក្នុងការការពារធនធានធម្មជាតិ ផលប៉ះពាល់លើការប្រកបមុខរបរតាមបែបប្រពៃណី និងអត្តសញ្ញាណជនជាតិដើមភាគតិចដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយដីធ្លីព្រៃឈើ និងធនធានធម្មជាតិ ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួង

អភិវឌ្ឍន៍ជនបទបានទទួលសំណើ សំណូមពរប្រជាពលរដ្ឋ ចំនួន ៣៥ ករណី បានដោះស្រាយចំនួន ១២ករណី ។

**២.២.១៥. ការងារយេនឌ័រ**

(គ្មានសកម្មភាព)

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

(គ្មានសកម្មភាព)

**២.២.១៧. ក្រុមការងារលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអភិវឌ្ឍន៍ជនបទ**

គិតត្រឹមចុង ខែកញ្ញា នេះ ស្ថានភាពភ្លៀងធ្លាក់ខ្លាំងជាបន្តបន្ទាប់នៅតាមបណ្តាខេត្តចំនួន០៦ ដែលក្រុមការងារលេខាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រសួងអភិវឌ្ឍន៍ជនបទបានទទួលរបាយការណ៍បឋមអំពីផលប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធជនបទមានដូចខាងក្រោម ៖

- **ខេត្តកំពង់ធំ**

ផ្លូវក្រាលក្រួសក្រហម និងកៅស៊ូ DBST ចំនួន ៣០ ខ្សែ មានប្រវែងសរុបចំនួន ៣៦០,១៥០ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង១០៤,០៥០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវប្រវែង១៦,៤០០ គីឡូម៉ែត្រ និងហូរច្រោះជើងទេរប្រវែង ៦៦,៦០០ គីឡូម៉ែត្រ។ ផ្លូវក្រាលក្រួសក្រហមចំនួន ២៤ខ្សែ និងកៅស៊ូចំនួន ៦ខ្សែ ដែលបានលិចទឹក និងរងផលប៉ះពាល់ស្ថិតក្នុងភូមិសាស្ត្រស្រុកប្រាសាទសំបូរ ស្រុកស្ទោង ស្រុកសណ្តាន់ ស្រុកកំពង់ស្វាយ ស្រុកសន្ទុក ស្រុកប្រាសាទបាល្ល័ង្គ និងក្រុងស្ទឹងសែន ។

- **ខេត្តសៀមរាប**

ផ្លូវក្រាលក្រួសក្រហមចំនួន ៣៦ ខ្សែ មានប្រវែងសរុបចំនួន ៣៧៨,៨៤២ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង ៧៥,២៥០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវប្រវែង ២៣,០២៥ គីឡូម៉ែត្រ និងហូរច្រោះជើងទេរប្រវែង ៤៤,៨៣០ គីឡូម៉ែត្រ ។ ផ្លូវក្រាលក្រួសក្រហមចំនួន ៣៦ខ្សែ ដែលបានលិចទឹក និងរងផលប៉ះពាល់ស្ថិតនៅភូមិសាស្ត្រប្រាសាទបាគង ស្រុកពួក ស្រុកសូទ្រនិគម ស្រុកស្វាយលើ ស្រុកជីក្រែង ស្រុកវ៉ារិន ស្រុកអង្គរធំ ស្រុកក្រឡាញ់ និងស្រុកស្រីស្នំ ។

- **ខេត្តពោធិ៍សាត់**

ផ្លូវក្រាលក្រួសក្រហម និងកៅស៊ូពីរជាន់ ចំនួន១៥ ខ្សែ មានប្រវែងសរុបចំនួន ១៨៥,៥០០ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង ២៨,៨៥០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវប្រវែង ២,៨៤០ គីឡូម៉ែត្រ និងហូរច្រោះជើងទេរប្រវែង ៩,៥៧០ គីឡូម៉ែត្រ ។ ផ្លូវក្រាលក្រួសក្រហមចំនួន ១៤ខ្សែ និងកៅស៊ូពីរជាន់ ចំនួន ១ខ្សែដែលលិចទឹក និងរងផលប៉ះពាល់ ស្ថិតនៅភូមិសាស្ត្រស្រុកកណ្តៀង ស្រុកតាលោសែនជ័យ ស្រុកក្រគរ និងស្រុកភ្នំក្រវ៉ាញ ។

- **ខេត្តព្រះវិហារ**

ផ្លូវក្រាលក្រួសក្រហម ចំនួន ៩ខ្សែ មានប្រវែងសរុបចំនួន ២០២,៩១០ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង ១៣,០៦០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវ ២,៦០០ គីឡូម៉ែត្រ និងហូរច្រោះ

ជើងទេប្រវែង ១០,២៣០ គីឡូម៉ែត្រ ។ ផ្លូវក្រាលក្រួសក្រហម ចំនួន ៩ខ្សែ ដែលលិចទឹក និងរងផលប៉ះពាល់ស្ថិតនៅភូមិសាស្ត្រស្រុកសង្គមថ្មី ស្រុកគូលែន ស្រុកជាំក្សាន្ត ស្រុករវៀង និងស្រុកជ័យសែន ។

- **ខេត្តបន្ទាយមានជ័យ**

ផ្លូវក្រាលក្រួសក្រហម កៅស៊ូ និងបេតុង ចំនួន ៤៥ខ្សែ មានប្រវែងសរុបចំនួន ៤៨០,៥៣៦ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង ១៣៥,២៥០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវ ២៩,០៤៥ គីឡូម៉ែត្រ និងហូរច្រោះជើងទេរប្រវែង ១១១,១៥០ គីឡូម៉ែត្រ ។ ផ្លូវក្រាលក្រួសក្រហម ចំនួន ៣៦ខ្សែ កៅស៊ូ ចំនួន ៦ខ្សែ និងបេតុងចំនួន ៣ខ្សែ ដែលបានលិចទឹក និងរងផលប៉ះពាល់ស្ថិតនៅភូមិសាស្ត្រស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកអូរជ្រៅ ស្រុកមង្គលបុរី ស្រុកស្វាយចេក ស្រុកថ្មពួក និងក្រុងសិរីសោភ័ណ។

- **ខេត្តឧត្តរមានជ័យ**

ផ្លូវក្រាលក្រួសក្រហម ចំនួន ៣០ខ្សែ មានប្រវែងសរុបចំនួន ២២៤,៨០០ គីឡូម៉ែត្រ ត្រូវបានលិចទឹកប្រវែង ៩៤,២០០ គីឡូម៉ែត្រ ដោយក្នុងនោះដាច់តួផ្លូវ ១,១១២ គីឡូម៉ែត្រ និងហូរច្រោះជើងទេរប្រវែង ៤០,០២០ គីឡូម៉ែត្រ ។ ផ្លូវក្រាលក្រួសក្រហម ចំនួន ៣០ខ្សែ ដែលបានលិចទឹក និងរងផលប៉ះពាល់ស្ថិតនៅភូមិសាស្ត្រស្រុកបន្ទាយអំពិល ស្រុកចុងកាល់ ស្រុកសំរោង ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ។

### ២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

#### ២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

គិតត្រឹមដំណាច់ខែកញ្ញានេះ គម្រោងសម្រេច៖

- បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ៧៤ ខ្សែ មានប្រវែងសរុប ១ ២២០,៤៦ គ.ម សម្រេចបាន ៩៧,៩០% នៅក្នុងខេត្តគោលដៅទាំង ១០
- បានទទួលការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី លើសំណើស្ថាបនាខ្សែផ្លូវបន្ថែម ប្រវែងសរុបប្រមាណ ៦៤,១១ គ.ម. ដើម្បីបានធ្វើការតភ្ជាប់ជាបណ្តាញនូវផ្លូវដែលនៅសល់មួយចំនួន និងតាមតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ នៅក្នុងខេត្តចំនួន ០៥ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ដោយប្រើប្រាស់ថវិកាដែលនៅសល់របស់គម្រោង ។

#### ២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ

- ការងារក្រាលក្រួសក្រហម ឬល្បាយថ្មកំទេ អនុវត្តឆ្នាំ២០២១ រយៈពេល៩ខែ ក្នុងឆ្នាំ ២០២២ នេះ គម្រោងសម្រេចបានចំនួន ១៥៩ អនុគម្រោង ប្រវែង ៥១១ ៧១២ ម៉ែត្រ នៃអនុគម្រោងដែលបានអនុម័តចំនួន ៧៦៣ អនុគម្រោង ប្រវែង ២ ៤៤៦ ២៣៧ ម៉ែត្រ
- ការអនុវត្តការងារសាងសង់បង្គន់សាធារណៈនៅសាលារៀន និងមណ្ឌលសុខភាព រយៈពេល៩ខែ ឆ្នាំ២០២២ គម្រោងសម្រេចបានចំនួន ៣៤ កិច្ចសន្យាស្មើនឹង ១៩០ បង្គន់ នៃកិច្ចសន្យាដែលបានចរចាចំនួន ៣៤ កិច្ចសន្យាស្មើនឹង ១៩០ បង្គន់
- ការងារជីកស្រះបានអនុវត្តបញ្ចប់ចំនួន ៤០៩ អនុគម្រោង ប្រវែង ៥៧៨ ៨៣៩ ម៉ែត្រ និងបាន និងកំពុងអនុវត្តចំនួន ០៥ អនុគម្រោង ប្រវែង ៥ ១៤០ ម៉ែត្រ

- ការងារក្រាលក្រួសក្រហម ឬល្បាយថ្មកំ អនុវត្តឆ្នាំ២០២២រយៈពេល៩ខែគម្រោងសម្រេចបាន ចំនួន ១១០ អនុគម្រោង ប្រវែង ៣៣៤ ៤៧២ម៉ែត្រ និងកំពុងអនុវត្តចំនួន ៤៩ អនុគម្រោង ប្រវែង ១៣៩ ៤៦៥ ម៉ែត្រ នៃអនុគម្រោងដែលបានអនុម័តចំនួន ១៥៩ អនុគម្រោង ប្រវែង ៤៧៣ ៩៣៧ ម៉ែត្រ ។

**២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង** ( Mekong Lancang Cooperation )

- គម្រោងបំពេញបន្ថែមលើគម្រោងសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន
  - បានចុះពិនិត្យខ្នងផ្ទះប្រជាពលរដ្ឋដែលត្រូវជួសជុលកែលម្អ និងសាងសង់បង្គន់អនាម័យ
  - បានចុះកុងត្រាជាមួយក្រុមហ៊ុនលើការងារជួសជុល កែលម្អផ្ទះ និងសាងសង់បង្គន់អនាម័យ ជូនប្រជាពលរដ្ឋទទួលផលចំនួន ៧០ គ្រួសារ
  - បានរៀបចំនីតិវិធីលទ្ធកម្ម សម្រាប់ការតបណ្តាញអគ្គិសនីជូនប្រជាពលរដ្ឋ
  - បាន និងកំពុងរៀបចំការបញ្ជាទិញសម្ភារ និងតបណ្តាញអគ្គិសនីតាមខ្នងផ្ទះ ដែលអនុវត្ត ដោយក្រុមហ៊ុនឯកជន ។
- គម្រោងចែកចាយទឹកស្អាត ដើម្បីអនាគតទាំងអស់គ្នា
  - បានចុះទៅណែនាំអំពីការធ្វើលទ្ធកម្មសហគមន៍ ចំនួន ០៤ សហគមន៍ នៅស្រុកគិរីវង់ ខេត្តតាកែវ
  - បានរៀបចំកិច្ចប្រជុំ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងឯកសារក្នុងការបង្កើតគណៈកម្មការសម្របសម្រួល និងឯកសារពាក់ព័ន្ធផ្សេងៗ សម្រាប់តបណ្តាញទឹកស្អាត ចូលក្នុងសហគមន៍
  - បានចុះបង្រៀន និងណែនាំដល់សហគមន៍ទាំង ០៤ អំពីការរៀបចំឯកសារនីតិវិធីលទ្ធកម្ម ពាក់ព័ន្ធនឹងការតបណ្តាញទឹកស្អាត ចូលក្នុងសហគមន៍
  - បានចុះត្រួតពិនិត្យបច្ចេកទេស ជីកដីបង្កប់ទុយោទឹក សម្រាប់តបណ្តាញទឹកស្អាតរបស់ សហគមន៍ទាំង ០៤
- គម្រោងពិពិធកម្មសេដ្ឋកិច្ចជនបទ សម្រាប់កសិករដែលមានចំណូលទាប
  - បានចុះត្រួតពិនិត្យ លើការសាងសង់ឃ្លាំងស្តុកបន្លែ និង ជង្រុកស្រូវ របស់សហគមន៍ទាំង ០៤
  - បានចុះទៅណែនាំអំពីការធ្វើកិច្ចលទ្ធកម្មសហគមន៍លើគម្រោងពិពិធកម្មសេដ្ឋកិច្ច ជនបទសម្រាប់កសិករ ដែលមានចំណូលទាប ចំនួន ០៤ សហគមន៍
  - បានរៀបចំកិច្ចប្រជុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងឯកសារក្នុងការបង្កើត គណៈកម្មការសម្របសម្រួល និងឯកសារពាក់ព័ន្ធផ្សេងៗសម្រាប់សាងសង់ឃ្លាំង ស្តុកបន្លែ និងជង្រុកស្រូវ
  - បានចុះប្រគល់ត្រាក់ទ័រចំនួន ០១ គ្រឿង ជូនដល់សហគមន៍គិរីឧត្តមតាអូរ និងណែនាំ ឲ្យសហគមន៍ទាំង ០៤ រៀបចំឯកសារនីតិវិធីលទ្ធកម្មនានា ដែលពាក់ព័ន្ធនឹងការ សាងសង់ឃ្លាំងស្តុកបន្លែ និងជង្រុកស្រូវ ។

### ២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា

- បានចុះត្រួតពិនិត្យការងារ និងសមិទ្ធផលគម្រោងនៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ជាមួយស្ថានទូតឥណ្ឌាប្រចាំកម្ពុជា ។

### ២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្ដាល ដោយសម្រេចបាន ១០០%
- បាន និងកំពុងសាងសង់ផ្លូវកញ្ចប់ទី ២ ចំនួន ៦ខ្សែ ប្រវែង ៤៥,៣២៨គីឡូម៉ែត្រ ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង សម្រេចបានចំនួន ៨៥,៨៤%
- បាន និងកំពុងសាងសង់ផ្លូវកញ្ចប់ទី ៣ ចំនួន ១៤ខ្សែ ប្រវែង ១៥៦,៤០គីឡូម៉ែត្រ ក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាបសម្រេចបាន ៨៨,២០% ។

### ២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២

- សាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៧៩,១៣៧ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តកណ្ដាល សម្រេចបាន ១០០%
- សាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៤០,៤១ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង សម្រេចបាន ១០០%។

### ២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា

- បាន និងកំពុងកែសម្រួលឯកសារបច្ចេកទេសជួសជុលកែលម្អផ្លូវក្នុងខេត្តកំពង់ចាម ប្រវែង ២០ គ.ម ឲ្យស្របតាមយោបល់របស់ធនាគារពិភពលោក
- បាន និងកំពុងបន្តសិក្សាបច្ចេកទេសជួសជុលកែលម្អផ្លូវ ក្នុងខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ
- ក្រុមការងារបច្ចេកទេសផ្លូវ និងក្រុមការងារបរិស្ថាន និងសង្គម បានចុះផ្សព្វផ្សាយ និងស្រង់ទិន្នន័យផលប៉ះពាល់ផ្លូវដែលស្នើដោយសហគមន៍កសិកម្មក្នុងខេត្តបាត់ដំបង ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ។

### ២.៣.៨. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា

- ទីតាំងភូមិទាំងអស់ នៃខេត្តគោលដៅចំនួន ០៣ គឺខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តពោធិ៍សាត់ ត្រូវបានកំណត់នៅលើផែនទី ដើម្បីរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- បញ្ចប់ដោយជោគជ័យការដេញថ្លៃសម្ភារៈធ្វើតេស្តគុណភាពផ្លូវ
- បញ្ចប់ពង្រាងលក្ខខណ្ឌ (TOR) ជ្រើសរើសទីប្រឹក្សាផ្នែកយេនឌ័រ
- បញ្ចប់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសខ្សែផ្លូវអាទិភាពចំនួន ៣៣ ខ្សែ ដែលមានប្រវែងសរុប ១៥០ គ.ម នៃផ្លូវជនបទ ដែលមានសក្ដានុពលក្នុងការវិនិយោគទាំងសហគមន៍ និងឯកជន ដោយមានការយល់ព្រមពីធនាគារពិភពលោក និងក្រសួងបរិស្ថាន
- សហការជាមួយក្រុមការងារក្រសួងបរិស្ថាន ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញខ្សែផ្លូវអាទិភាព ដែលបានជ្រើសរើស និងប្រមូលទិន្នន័យផ្លូវជនបទ (ស្ថានភាពផ្លូវ និងរចនាសម្ព័ន្ធ)

- បានធ្វើការវាយតម្លៃនិងសិក្សាលម្អិត នៃតម្រូវការទឹកស្អាតនៅតាមខេត្តគោលដៅ ។

**២.៣.៩. គម្រោងកែលម្អផ្លូវជនបទដំណាក់កាលទី៣ (RRIP III)**

- បាន និងកំពុងសាងសង់ ផ្លូវក្រាលកៅស៊ូពីរជាន់ក្រោមហិរញ្ញប្បទានរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ២០ ខ្សែ ប្រវែងសរុប ៣៤០,៨០ គ.ម នៅក្នុងខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តក្រចេះ សម្រេចបាន ៧០,៣៧%
- បាន និងកំពុងសាងសង់ ផ្លូវក្រាលកៅស៊ូពីរជាន់ក្រោមហិរញ្ញប្បទានរបស់សាធារណរដ្ឋកូរ៉េ (EDCF) ចំនួន ៣៨ខ្សែ ប្រវែងសរុប ៣៦៥,២៤ គ.ម នៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកណ្តាល សម្រេចបាន ១៧,១៣% ។

**២.៣.១០. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល**

- រយៈពេល ៩ខែ ដើមឆ្នាំ២០២២នេះ ក្រសួងបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៤៥ ក្នុងនោះក្រសួងបានទទួលរបាយការណ៍សរុបចំនួន ២៣អង្គការ។ លទ្ធផលនៃការអនុវត្តរបស់អង្គការទាំង ២៣មាន ៖ សាងសង់សាលារៀនបាន ៥ខ្នង សាងសង់ផ្ទះជូនជនក្រីក្របាន ២៦ខ្នង។ ការងារទឹកស្អាត ជីកស្រះបាន ៧៤ស្រះ សាងសង់អណ្តូងស្នប់បានថ្មីបាន ១៨២អណ្តូង សាងសង់បង្គន់អនាម័យបាន ៦៨២១បង្គន់។ សាងសង់អាងត្រងទឹកភ្លៀង ៦៩៤អាង សាងសង់ប្រព័ន្ធចែកចាយទឹកបាន ៥៦ភូមិ។ សាងសង់ កន្លែងលាងដៃបាន ២៥៣៨កន្លែង ផលិតធុងសម្រាមដាក់ក្នុងសហគមន៍បាន ១១៤ធុង ចែកធុងទឹកចំនួន ១១១ធុង ផលិតធុងចម្រោះបាន ២០៣៩ធុង សាងសង់ឡដុតសម្រាមក្នុងសហគមន៍ចំនួន ២០កន្លែង ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលខ្លីចំនួន ៦២០វគ្គ ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- កង្វះឧបករណ៍ពិសោធន៍មួយចំនួន សម្រាប់ប្រើប្រាស់ទាំងក្នុងមន្ទីរពិសោធន៍ និងការងារពិសោធន៍នៅការដ្ឋានផ្ទាល់
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- មានភ្លៀងធ្លាក់ច្រើនប៉ះពាល់ការងារថែទាំ និងសាងសង់ផ្លូវជនបទ ។

### ៣.២. ទិសដៅតាមអាទិភាព

- បញ្ចប់ការកែលម្អផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បញ្ចប់ការកែលម្អផែនការថវិកាឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តចុះតាមដាន និងវាយតម្លៃការអនុវត្តផែនការថវិកាកម្មនៅតាមរាជធានី ខេត្ត
- ពិនិត្យនិងកែសម្រួលគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០
- ផ្តួចផ្តើមរៀបចំផែនការអភិវឌ្ឍន៍ជនបទ ៥ ឆ្នាំបន្ត ២០២៣-២០២៨
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ានសម្រាប់រៀបចំផែនការមេអាស៊ាន ២០២២-២០២៦
- បន្តចុះពិនិត្យការអនុវត្តផែនការសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល

- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពឯកសារសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ផ្លូវជនបទ
- ត្រៀមចុះត្រួតពិនិត្យផែនការជួសជុលផ្លូវទូទាំងរាជធានី-ខេត្ត
- បន្តការងារធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌផ្លូវជនបទ
- បន្តពង្រឹងសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីបច្ចេកទេសពិសោធន៍ក្នុងការអនុវត្តការងារពិសោធន៍ តាមរយៈការវាយតម្លៃ និងត្រួតពិនិត្យទៅលើគុណភាព រយៈពេល និងលទ្ធផលនៃការពិសោធន៍ (Frequency Test)
- រៀបចំពង្រាងគោលការណ៍ណែនាំគតិយុត្ត និងបទដ្ឋានបច្ចេកទេសរបស់មន្ទីរពិសោធន៍
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- រៀបចំកិច្ចប្រជុំជាមួយប្រធានមន្ទីរ អនុប្រធានមន្ទីរទទួលបន្ទុក និងប្រធានការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច ទាំង ១៥ ខេត្ត ចូលរួមកិច្ចប្រជុំពិភាក្សាការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច អំពីផែនការសកម្មភាព បញ្ហាប្រឈម និងទិសដៅការងារបន្ត
- រៀបចំឡើងវិញនូវនិតិវិធីចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តចុះវាយតម្លៃកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច និងសិក្សាស្រាវជ្រាវ អំពីប្រពៃណីវប្បធម៌ ទំនៀមទម្លាប់ជនជាតិដើមភាគតិចនីមួយៗឱ្យបានច្បាស់លាស់
- បន្តតាមដាន និងជំរុញការទទួលស្គាល់អត្តសញ្ញាណពីអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ស្រុក មន្ទីរអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលខេត្ត ។

## ៤.សេចក្តីសន្និដ្ឋាន

រយៈពេល ៩ខែ ដើមឆ្នាំ២០២២ នេះ ផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ-១៩ ត្រូវបាន

កាត់បន្ថយ ។ គ្រប់សកម្មភាពក្នុងផែនការឆ្នាំ២០២២ ត្រូវបានអនុវត្ត និងមានវឌ្ឍនភាពជាច្រើន រួមមាន ការងារសាងសង់ ជួសជុលថែទាំផ្លូវជនបទ ការងារមន្ទីរពិសោធន៍ផ្លូវជនបទ ការងារផ្គត់ផ្គង់ ទឹកស្អាត និងអនាម័យជនបទ ការអភិវឌ្ឍសហគមន៍ជនបទ ការងារសេដ្ឋកិច្ចជនបទ ការងារបណ្តុះបណ្តាលជំនាញមូលដ្ឋាននៅតាមមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទទាំង១៥ ។ កិច្ចសហការ ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ដើម្បីចុះត្រួតពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធជនបទបណ្តាលមកពីជំនន់ទឹកភ្លៀង និងត្រៀមលក្ខណៈស្តារឡើងវិញក្រោយបញ្ចប់ទឹកជំនន់។ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានខេត្តចំនួនពីរក្លាយជាខេត្តដែលបានបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល(ODF) គឺខេត្តស្វាយរៀង និងខេត្តព្រៃវែង និងគ្រោងបន្តទៅខេត្តមួយចំនួនទៀត ។

ដោយឡែកក្រោមកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ាន គម្រោងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលក្រសួងបានសម្រេចវឌ្ឍនភាពជាច្រើនដូចមានក្នុងរបាយការណ៍ខាងលើ ។

លទ្ធផលដែលក្រសួងសម្រេចបានខាងលើ បាននិងកំពុងរួមចំណែកដោះស្រាយបញ្ហា និងការប្រឈមនានានៅតាមតំបន់ជនបទ ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងក្នុងការជំរុញកំណើនប្រាក់ចំណូលតាមគ្រួសារនៅជនបទ និងលើកកម្ពស់សុខុមាលភាពប្រជាជនជនបទឲ្យបានល្អប្រសើរ ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**